# ការចេះអាន និងសរសេរនៅក្នុងឆ្នាំដំបូងៗ

ពាក្យ “ការចេះអាន និងសរសេរ” មានន័យផ្សេងៗពីគ្នា អាស្រ័យលើអ្នកដែលកំពុងប្រើវា។ "ការចេះអាន និងសរសេរ" សំដៅទៅលើជំនាញ និងចំណេះដឹងដ៏ទូលំទូលាយជាច្រើនដែលអនុញ្ញាតឱ្យមនុស្សដែលចេះអក្សរធ្វើទំនាក់ទំនង រៀន និងចូលរួមក្នុងសង្គម។

ការចេះអាន និងសរសេរ មានន័យថាការបង្រៀន និងការរៀនអំពី៖

- ភាសាផ្ទាល់មាត់
- ការអាន និង
- ការសរសេរ។

ទិដ្ឋភាពនីមួយៗនៃបណ្ដាទិដ្ឋភាពនៃការចេះអាន និងសរសេរទាំងនេះ ទាក់ទងនឹងជំនាញ និងចំណេះដឹងខុសៗគ្នា។

នៅដើមឆ្នាំដំបូង ភាសាផ្ទាល់មាត់ ការអាន និងការសរសេរត្រូវបានបង្រៀនទាំងដាច់ដោយឡែកពីគ្នា និងដោយរួមជាមួយគ្នា។ ពេលខ្លះមានមេរៀនផ្លូវការដែលគេអាចស្គាល់យ៉ាងងាយស្រួលថាជាការរៀនសូត្រអំពីចំណេះខាងការអាន និងសរសេរ។

នៅពេលផ្សេងទៀត ជំនាញក្នុងការចេះអាន និងសរសេរ ព្រមទាំចំណេះដឹងផងដែរត្រូវបានបញ្ចូលទៅក្នុងហ្គេម ការច្រៀង និងសកម្មភាពលេងនានា។ សិស្សអាចនឹងមិនដឹងថាទាំងនេះគឺជាចំណេះខាងការអាន និងសរសេរ ប៉ុន្តែពួកគេទាំងអស់មានតួនាទីសំខាន់ក្នុងការបង្រៀនជំនាញ និងចំណេះដឹងដែលត្រូវការដើម្បីចេះអក្សរ។

ការរៀនសូត្រដែលកើតឡើងនៅក្នុងផ្នែកមុខវិជ្ជាផ្សេងទៀតដូចជា គណិតវិទ្យា និងវិទ្យាសាស្ត្រក៏រួមបញ្ចូលនូវទិដ្ឋភាពនៃការបង្រៀនអំពីការចេះអាន និងសរសេរដែលមានលក្ខណៈជាក់លាក់ចំពោះមុខវិជ្ជាទាំងនោះផងដែរ។

## ភាសាផ្ទាល់មាត់

ពេលខ្លះគេហៅថា “ការនិយាយ និងការស្ដាប់” នៅក្នុងសាលារៀន ភាសាផ្ទាល់មាត់ផ្ដល់ជាមូលដ្ឋានគ្រឹះសម្រាប់ការរៀនជំនាញក្នុងការចេះអាន និងសរសេរផ្សេងទៀត។

នៅសាលារៀន កុមាររៀនភាសាផ្ទាល់មាត់តាមរយៈ៖

- ការចូលរួមពិភាក្សាក្នុងថ្នាក់រៀនជាថ្នាក់ទាំងមូល ជាក្រុមតូចៗ និងជាគូ
- ការនិយាយសម្រាប់គោលបំណងខុសៗគ្នា ឧទាហរណ៍ ការចែករំលែកអំពីការចូលចិត្ត និងការមិនចូលចិត្ត
- ការអានឱ្យឮខ្លាំងៗ ជាមួយនឹងការពិភាក្សា និងការសន្ទនាអំពីសៀវភៅ
- ការច្រៀងចំរៀង ការសូត្រធម៌ ការសូត្រកំណាព្យ និងពាក្យចួន
- ការនិយាយនៅមុខសិស្សក្នុងថ្នាក់សម្រាប់គោលបំណងខុសៗគ្នា ឧទាហរណ៍ ការចែករំលែកនូវអ្វីដែលពួកគេបានធ្វើនៅចុងសប្ដាហ៍
- ការស្ដាប់គ្រូ និងមិត្តរួមថ្នាក់។

ជូនកាល ជំនាញភាសាផ្ទាល់មាត់សំខាន់ៗមួយចំនួនដែលកុមារតូចៗនឹងអភិវឌ្ឍក្នុងអំឡុងពេលរៀនឱ្យចេះអាន និងសរសេរ រួមមាន៖

- ការស្ដាប់ និងការយល់ដឹងតាមការណែនាំផ្ទាល់មាត់

© 2021 Commonwealth of Australia, unless otherwise indicated. Creative Commons Attribution 4.0, unless otherwise indicated.

- ការស្តាប់ និងការយល់ដឹងរឿងនានាដោយការអានឮខ្លាំងៗ
- ការសួរសំណួរ ឬការលើកសំណើ និងការស្តាប់ចម្លើយនានា
- ការបង្ហាញអារម្មណ៍ គំនិត និងយោបល់ដោយផ្ទាល់មាត់
- ការនិយាយជាប្រយោគពេញលេញ
- ការឮពាក្យដាច់ដោយឡែកពីគ្នានៅក្នុងប្រយោគមួយ
- ការឮ និងការចម្លងតាមលំនាំសំឡេង ដូចជាពាក្យចួន។

ទាំងនេះគឺជាវិធីមួយចំនួនដែលអ្នកអាចលើកទឹកចិត្តដល់ភាសាផ្ទាល់មាត់នៅផ្ទះ៖

- និយាយជាមួយកូនរបស់អ្នក សួរពួកគេនូវសំណួរនានាដែលត្រូវការច្រើនជាងចម្លើយ “បាទ/ចាស” ឬ“ ទេ”។ សួរពួកគេសុំយោបល់ មតិ ចំណង់ចំណូលចិត្តរបស់ពួកគេ និងផ្តល់ការពន្យល់ ឬការកែតម្រូវនានាដែលលើកទឹកចិត្តឱ្យពួកគេនិយាយជាប្រយោគកាន់តែវែង និងកាន់តែស្មុគស្មាញ។
- ស្តាប់ដោយយកចិត្តទុកដាក់ និងដោយមានការឆ្លើយតបចំពោះចម្លើយរបស់កូនអ្នក។
- លេងហ្គេមនិយាយ (រថយន្តអាចជាកន្លែងល្អសម្រាប់រឿងនេះ) ដូចជា I spy with my little eye, Twenty questions, Celebrity heads និងTaboo.
- ធ្វើអ្វីៗជាមួយគ្នា ហើយនិយាយពីអ្វីដែលអ្នកបានធ្វើ។ ធ្វើម្ហូប ឬថែសួនជាមួយគ្នា ធ្វើដំណើរតាមរថយន្តក្រុង ឬរថភ្លើង ទៅលេងអាងហែលទឹក ឬឧទ្យានក្នុងតំបន់ ដើរលេងតាមព្រៃ ឬនៅជុំវិញតំបន់ជិតខាងរបស់អ្នក។ នេះនឹងធ្វើឱ្យកុមារស្គាល់វាក្យសព្ទ ពាក្យបច្ចេកទេស និងរចនាសម្ព័ន្ធប្រយោគខុសៗគ្នា។
- ការលេងជាមួយគ្នាតាមរបៀបដែលបានគ្រោងទុក ឬមិនបានគ្រោងទុក អនុញ្ញាតឱ្យកុមារធ្វើការពិសោធន៍ជាមួយនឹងការនិយាយសម្រាប់គោលបំណងខុសៗគ្នា និងលើកទឹកចិត្តឱ្យមានការច្នៃប្រឌិត និងការស្រមើលស្រមៃ។ គូរគំនូរជាមួយគ្នា ប្រើប្រាស់ការលេងដូហ្វ (dough) ជីកក្នុងដីកខ្វក់ខ្លះៗ លេងស្លៀកពាក់ ធ្វើផ្លូវសម្រាប់រថយន្តក្មេងលេង លេងជាមួយអាយ៉ងឬលេងបៀរនិងហ្គេមក្តារ។
- ច្រៀងចម្រៀង ពាក្យកំណាព្យចួន ឬចម្រៀង ឬកំណាព្យល្ងីល្ងើ។ ផ្លាស់ប្តូរពាក្យទៅវិញទៅមក ឬដាក់ជំនួសឈ្មោះនិងកន្លែងដែលអ្នកនិងកូនរបស់អ្នកស្គាល់។

© 2021 Commonwealth of Australia, unless otherwise indicated. Creative Commons Attribution 4.0, unless otherwise indicated.

## ការអាន

កុមារអានដើម្បីភាពរីករាយ និងដើម្បីរៀនសូត្រ និងស្វែងយល់នៅដើមឆ្នាំដំបូង និងនៅទូទាំងការរៀនសូត្រនៅសាលារៀនរបស់ពួកគេ។ គោលបំណងនៃការអានគឺដើម្បីយល់ ឬដឹងបានទូលំទូលាយអំពីសៀវភៅ អត្ថបទ ឬគេហទំព័រដែលខ្លួនកំពុងអាន។

នៅសាលារៀន កុមាររៀនអានតាមរយៈ

- ការស្ដាប់ និងការឆ្លើយតបទៅនឹងរឿង កំណាព្យ សៀវភៅមិនមែនប្រលោមលោកប្រឌិត និងគេហទំព័រនានាដែលគ្រូបង្រៀនបានអានឮខ្លាំងៗ
- ការអានព្រមជាមួយគ្រូបង្រៀន និងមិត្តរួមថ្នាក់
- ការអានជាក្រុមតូចៗនិងជាលក្ខណៈបុគ្គលជាមួយគ្រូ
- ការព្យាយាម និងអនុវត្តជំនាញដែលកំពុងរីកចម្រើនរបស់ពួកគេដោយឯករាជ្យ។
- ក្នុងអំឡុងពេលសិក្សាឱ្យចេះអាន និងសរសេរដំបូង កុមារនឹងអភិវឌ្ឍជំនាញអាន និងចំណេះដឹងសំខាន់ៗមួយចំនួន រួមមានដូចតទៅ៖
- សៀវភៅ និងគេហទំព័រត្រូវបានបង្កើតឡើងដោយអ្នកនិពន្ធ និងជាង គំនូរសម្រាប់គោលបំណងជាក់លាក់។
- ពាក្យដែលបានបោះពុម្ពនៅលើទំព័រមានអត្ថន័យ ហើយអាចត្រូវបានប្រើដើម្បីបង្កើតជាប្រយោគនានា ដែលគេអាចផ្សំជាផ្នែកនៃសំណេរកាន់តែវែង។
- វណ្ណយុត្តិជួយអ្នកអានឱ្យបង្កើតអត្ថន័យនៃពាក្យ និងប្រយោគនានា។
- រូបភាព និងគំនូរបង្ហាញនានាក៏ចូលរួមចំណែកនៅក្នុងការបង្កើតអត្ថន័យនៅក្នុងសៀវភៅស្រមើស្រមៃនិងសៀវភៅព័ត៌មាន អត្ថបទ និងគេហទំព័រនានា។
- បទពិសោធន៍របស់អ្នកអានអំពីពិភពលោក និងសៀវភៅផ្សេងទៀត ជួយឱ្យពួកគេយល់អំពីអ្វីដែលពួកគេបានអាន។
- អ្នកអានម្នាក់ៗឆ្លើយតបខុសពីគ្នាទៅនឹងអ្វីដែលពួកគេបានអាន។

វាជាការសំខាន់ក្នុងការលើកទឹកចិត្តឱ្យមានការអាននៅផ្ទះ។

- ទស្សនាបណ្ណាល័យក្នុងតំបន់របស់អ្នក ហើយឱ្យកុមារជ្រើសរើសសៀវភៅរូបភាព ឬសៀវភៅដែលមិនមែនប្រលោមលោកប្រឌិតដើម្បីខ្ចី។
- ដេកនៅកន្លែងសម្រាក ហើយអានសៀវភៅដែលកូនរបស់អ្នកចូលចិត្តឡើងវិញឱ្យឮខ្លាំងៗឱ្យពួកគេស្ដាប់។ ណែនាំកូនរបស់អ្នកឱ្យដឹងសៀវភៅនានាដែលអ្នកចូលចិត្តពេលអ្នកនៅក្មេង។ និយាយ និងចែករំលែកការរីករាយ និងការកោតសរសើររបស់អ្នកចំពោះសៀវភៅដែលអ្នកបានអានជាមួយគ្នា។
- ស្ដាប់សៀវភៅសំឡេងទាំងអស់គ្នា។ (នេះជារឿងល្អដែលគួរធ្វើក្នុងការធ្វើដំណើរតាមរថយន្តចម្ងាយឆ្ងាយ។) និយាយអំពីការឆ្លើយតបរបស់អ្នកចំពោះរឿង។
- ផ្ដល់សៀវភៅជាកាដូ។ ចាត់ទុកសៀវភៅជារបស់មានតម្លៃ និងពិសេស។
- ទស្សនាហាងលក់សៀវភៅប្រើរួច និងហាងអូឌីដើម្បីស្វែងរកចំណងជើង ឬអ្នកនិពន្ធដែលចូលចិត្តឬថ្មី។
- និយាយអំពីសៀវភៅដែលខ្លួនចូលចិត្ត ប្រភេទរឿង អ្នកនិពន្ធ និងអ្នកគូររូប។ លើកទឹកចិត្តឱ្យកូនរបស់អ្នកចែករំលែកការឆ្លើយតបផ្ទាល់ខ្លួនរបស់ពួកគេចំពោះសៀវភៅ និងហេតុផលសម្រាប់ការចូលចិត្ត និងការមិនចូលចិត្តរបស់ពួកគេ។

© 2021 Commonwealth of Australia, unless otherwise indicated. Creative Commons Attribution 4.0, unless otherwise indicated.

- ត្រូវប្រាកដថាអ្នកឱ្យកូនអ្នកឃើញអ្នកកំពុងអានអ្វីដែលអ្នកចាប់អារម្មណ៍ (សៀវភៅ កាសែត ទស្សនាវដ្តី ប៉ុន្តែមិនមែនទូរសព្ទនោះទេ!)។
ទុកពេលវេលាពិសេសរាល់ថ្ងៃដើម្បីឱ្យគ្រួសារទាំងមូលអង្គុយនៅកន្លែងណាមួយដែលមានផាសុខភាព ហើយអានសៀវភៅផ្ទាល់ខ្លួនរបស់ពួកគេជាមួយគ្នា។
- ចង្អុលបង្ហាញអក្សរដែលបានបោះពុម្ពនៅជុំវិញផ្ទះ និងកន្លែងដែលអ្នកទៅកាន់ដូចជា ឈ្មោះផ្លូវ ស្លាកហាង កញ្ចប់អាហារ និងផែនទី។

## ការសរសេរ

នៅពេលពួកគេរៀនសរសេរ និងអនុវត្តការសរសេរនៅឆ្នាំដំបូងៗ កុមារនឹងទាញយកជំនាញភាសាផ្ទាល់មាត់ និងជំនាញអាន និងចំណេះដឹងរបស់ពួកគេមកប្រើ។

នៅសាលារៀន កុមាររៀនសរសេរ តាមរយៈ៖

- ការក្រឡេកមើលសំណេររបស់អ្នកដទៃដោយផិតដល់ រួមទាំងគ្រូ និងអ្នកនិពន្ធដែលបានបោះពុម្ពផ្សាយ
- បំផុសគំនិតជាមួយគ្រូ និងមិត្តរួមថ្នាក់
- ការធ្វើផែនការសម្រាប់ការសរសេរជាថ្នាក់ នៅក្នុងក្រុមតូចៗ ឬជាគូ និងជាបុគ្គល
- ការសរសេររួមគ្នាជាថ្នាក់ ដោយមានការណែនាំពីគ្រូ
- ការសរសេរជាមួយដៃគូ និងដោយឯករាជ្យ
- ចែករំលែកសំណេររបស់ពួកគេ និងនិយាយជាមួយគ្រូ និងមិត្តរួមថ្នាក់អំពីសំណេរផ្ទាល់ខ្លួនរបស់ពួកគេ
- ការសរសេរសម្រាប់គោលបំណងខុសៗគ្នា។

ក្នុងអំឡុងពេលរៀនឱ្យចេះអាន និងសរសេរដំបូង កុមារនឹងអភិវឌ្ឍជំនាញសរសេរ និងចំណេះដឹងសំខាន់ៗមួយចំនួន។ ពួកគេនឹងរៀនថាអ្នកនិពន្ធ៖

- សរសេរសម្រាប់គោលបំណង និងទស្សនិកជនផ្សេងៗគ្នា
- អាចមានការច្នៃប្រឌិត និងការស្រមើលស្រមៃ
- ជ្រើសរើសពាក្យរបស់ពួកគេ រចនាសម្ព័ន្ធប្រយោគ និងប្លង់នៃការសរសេររបស់ពួកគេដើម្បីជួយបំពេញទៅតាមគោលបំណងនៃការសរសេររបស់ពួកគេ
- ប្រើទំហំអក្សរ ទ្រង់ទ្រាយ និងទិសដៅឱ្យស៊ីចង្វាក់គ្នានៅពេលពួកគេសរសេរ
- ប្រើចំណេះដឹងប្រកបពាក្យដើម្បីប្រកបឱ្យមានភាពប្រាកដប្រជា។ (ចំណេះដឹងប្រកបរួមបញ្ចូលទាំងទំនាក់ទំនងរវាងសំឡេងនៅក្នុងពាក្យមួយ និងអក្សរនានាដែលប្រើដើម្បីតំណាងឱ្យសំឡេងនោះ លំនាំអក្សរនៅក្នុងពាក្យ និងទម្លាប់នៃការប្រកបដែលត្រឹមត្រូវ។)

សាកល្បងគំនិតមួយចំនួនទាំងនេះដើម្បីសរសេរជាមួយកូនរបស់អ្នកនៅផ្ទះ។

- បង្កើតជាបញ្ជីមួយមុនពេលទៅទិញគ្រឿងទេស។
- សរសេរសំបុត្រ លិខិតអញ្ជើញ ប័ណ្ណស្វាគមន៍ ប័ណ្ណប្រៃសណីយ៍ និងអ៊ីមែលទៅគ្រួសារនិងមិត្តភក្តិ។
- ចម្លងទុករូបមន្តធ្វើម្ហូបរបស់ជីដូនដែលអ្នកចូលចិត្ត។
- សរសេរបញ្ជីនៅពេលអ្នកគ្រោងសកម្មភាពគ្រួសារផ្សេងៗដូចជា ការវេចខ្ចប់សម្រាប់ថ្ងៃវិស្សមកាល ឬរៀបចំពិធីជប់លៀង។
- ដាក់ស្លាកគំនូររបស់កុមារ។ ឱ្យកុមារនិយាយ និងសរសេរអំពីគំនូររបស់ពួកគេ។

© 2021 Commonwealth of Australia, unless otherwise indicated. Creative Commons Attribution 4.0, unless otherwise indicated.

- សាកល្បងស្ថានភាពលេងដើរតួខ្លះដែលពាក់ព័ន្ធនឹងការសរសេរ ឧទាហរណ៍ លេងជាភោជនីយដ្ឋាន និងសរសេរការកុម្ម៉ង់ទិញរបស់អតិថិជន លេងជាគ្រូពេទ្យនិងយកព័ត៌មានលម្អិតរបស់អ្នកជំងឺ លេងជាប៉ូលិស និងសួរសាក្សីសម្រាប់ព័ត៌មានលម្អិតនៃការបុករថយន្ត។



Erin មានអាយុ 4½ ឆ្នាំ បានកត់ត្រាទុកការកុម្ម៉ង់ឈីសដាក់លើនំប៉័ងសម្រាប់អាហារថ្ងៃត្រង់របស់ម្ដាយនាង។

© 2021 Commonwealth of Australia, unless otherwise indicated. Creative Commons Attribution 4.0, unless otherwise indicated.